ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៧៣...០៧...១១០...ប្រ.ក

លិខិតចូល
ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ 2007

# ប្រកាស

## ស្តីពី

## បទបញ្ជានៃការដឹកជញ្ជូនធនប័ត្រ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ. ៨៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិ នៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គបេឡា នៃធនាគារជាតិនៃកម្ពុជា
- យោងតាមការសម្រេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧

## សំ រេ ច

**ប្រការ ១.-** មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានិងបុគ្គលទាំងឡាយណាដែលពាក់ព័ន្ធក្នុងការដឹកជញ្ជូនធនប័ត្រជារូបិយវត្ថុ ឬ រូបិយប័ណ្ណ តទៅនេះហៅថា "ធនប័ត្រ" ត្រូវរក្សាការសម្ងាត់ឱ្យបានដាច់ខាតដើម្បីធានាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់នៃការដឹកជញ្ជូនឱ្យដល់គោលដៅដោយសុវត្ថិភាព ។

**ប្រការ ២.-** នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា ត្រូវសហការជាមួយខុទ្ទកាល័យ ដើម្បីអនុវត្តការងារដឹកជញ្ជូនធនប័ត្រ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន តាមនីតិវិធី និងវិធានការដូចមានចែងខាងក្រោមនេះ ។

**ប្រការ ៣.-** នៅពេលមានតម្រូវការក្នុងការដឹកជញ្ជូនធនប័ត្រ នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡាត្រូវ ÷

- រៀបចំធនប័ត្រតាមចំនួន ប្រភេទ និងវេចខ្ចប់ យោងតាមការណែនាំ និងបទដ្ឋានជាធរមាន ។
- រៀបចំបែបបទដើម្បីស្នើទៅខុទ្ទកាល័យ ដោយបញ្ជាក់អំពីបញ្ជីឈ្មោះមន្ត្រីបុគ្គលិកចូលរួម និងមន្ត្រីដែលមានភារកិច្ចទទួលខុសត្រូវរួមក្នុងការដឹកជញ្ជូននេះ ។ នៅក្នុងឯកសារទាំងនោះត្រូវបញ្ជាក់អំពីចំនួនរថយន្ត កាលបរិច្ឆេទ ពេលវេលា និងសំណូមពរផ្សេងៗទៀត ដែលចាំបាច់ក្នុងការដឹកជញ្ជូន ។

- ចំនួនរថយន្តត្រូវគណនាទៅតាមទំហំ និងទម្ងន់នៃកញ្ចប់ធនប័ត្រ ដែលសមស្របតាមប្រភេទរថយន្តនិមួយៗអាចផ្ទុកបាន ។ នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនៃការដឹកជញ្ជូននិងពេលវេលាទៅភាគីពាក់ព័ន្ធម្ខាងទៀត ។

**ប្រការ ៤.-** ពេលទទួលបានសំណើដឹកជញ្ជូនធនប័ត្រពីនាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា ខុទ្ទកាល័យត្រូវរួសរាន់រៀបចំដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឱ្យបានទាន់ពេលវេលានូវការងារទាំងឡាយដូចខាងក្រោមនេះ÷

- ធ្វើលិខិតបញ្ជាបេសកកម្មជូនមន្ត្រីបុគ្គលិកតាមបញ្ជីឈ្មោះដែលនាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡាបានស្នើមក ។
- ធ្វើលិខិតបញ្ជាបេសកកម្មដល់កងការពារសន្តិសុខ អ្នកបើកបររថយន្ត ដែលត្រូវបានចាត់តាំងទទួលភារកិច្ចក្នុងបេសកកម្មដឹកជញ្ជូន ។
- រៀបចំប្រាក់សម្រាប់ចំណាយបេសកកម្មដែលពាក់ព័ន្ធក្នុងការដឹកជញ្ជូនមួយលើកៗ ។
- រៀបចំរថយន្តសម្រាប់ការពារ និងរថយន្តដឹកជញ្ជូន យោងតាមសំណើរបស់នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា ។ រថយន្តការពារសន្តិសុខ និងរថយន្តដឹកធនប័ត្រត្រូវរក្សាការពារត្រួតពិនិត្យបច្ចេកទេសជាប្រចាំ ត្រៀមប្រេងឥន្ធនៈគ្រប់ចំនួន ត្រៀមសំភារៈគ្រប់គ្រាន់សម្រាប់ ជួសជុល និងផ្លាស់ប្តូរបន្ទាន់ ដើម្បីធានាបានសុវត្ថិភាពក្នុងពេលដឹកជញ្ជូន ។
- រថយន្តទាំងនោះ ត្រូវតែបានរក្សាទុកឱ្យនៅទំនេរសម្រាប់តែការប្រើប្រាស់ក្នុងការដឹកជញ្ជូនធនប័ត្រតែប៉ុណ្ណោះ ដោយមិនត្រូវយកទៅប្រើប្រាស់ក្នុងទិសដៅផ្សេងពីនេះឡើយ ។

**ប្រការ ៥.-** មន្ត្រីបុគ្គលិក កងការពារសន្តិសុខ អ្នកបើកបររថយន្តទាំងអស់ដែលពាក់ព័ន្ធនឹងទទួលបានការចាត់តាំងឱ្យចូលរួមក្នុងការងារដឹកជញ្ជូនធនប័ត្រ ត្រូវប្រកាន់ខ្ជាប់នូវវិន័យនិងឥរិយាបថដូចខាងក្រោម÷

- រក្សាការសម្ងាត់ដាច់ខាតដោយមិនបញ្ចេញព័ត៌មានឱ្យជនណាផ្សេងដឹងឡើយ ទោះបីជាអ្នកទាំងនោះជាសាច់សារលោហិត ឬញាតិមិត្តជិតស្និទ្ធយ៉ាងណាក៏ដោយ ។
- ត្រូវមកដល់កន្លែងដើម្បីទទួលភារកិច្ចរបស់ខ្លួនយ៉ាងយឺតបំផុត ៣០នាទី មុនពេលចេញដំណើរតាមពេលម៉ោងដែលបានកំណត់ ។
- ត្រូវគោរពតាមលក្ខខណ្ឌនៃការបញ្ចេញបញ្ចូលឃ្លាំង និងការប្រគល់ឬទទួលធនប័ត្រឱ្យបានត្រឹមត្រូវតាមបទបញ្ជា និងសេចក្តីណែនាំជាធរមាន ។
- ត្រូវទទួលទានដំណេកឱ្យបានគ្រប់គ្រាន់នៅពេលយប់មុនថ្ងៃចេញដំណើរ ។
- មិនត្រូវប្រើទូរស័ព្ទទាក់ទងនៅមុនពេល ឬកំពុងធ្វើដំណើរដឹកជញ្ជូន លើកលែងតែប្រធានទទួលខុសត្រូវនៃក្រុមនិមួយៗ សម្រាប់ទាក់ទងតែក្នុងការដឹកជញ្ជូនប៉ុណ្ណោះ មិនអាចទាក់ទងផ្សេងពីនេះបានឡើយ ។
- អ្នកបើកបរមិនត្រូវប្រើទូរស័ព្ទជាដាច់ខាតក្នុងពេលកំពុងបើកបរ ។

- ក្បួនរថយន្តត្រូវបើកបរក្នុងល្បឿនមធ្យម មិនឱ្យលឿនពេក និងយឺតពេក ហើយមិនត្រូវឱ្យដាច់ចេញឆ្ងាយពីគ្នាឡើយ ។
- មិនត្រូវសេពសុរានៅមុនពេលចេញដំណើរ ឬជក់បារីនៅក្នុងពេលធ្វើដំណើរឡើយ ។
- កងការពារសន្តិសុខត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងត្រួតពិនិត្យអាវុធរបស់ខ្លួនដោយត្រូវចាក់សោសុវត្ថិភាព និងត្រូវមានស្មារតីប្រុងប្រយ័ត្នជានិច្ច ដើម្បីត្រៀមខ្លួនមានប្រតិកម្មទាន់ពេលវេលានៅពេលដែលមានហេតុការណ៍កើតឡើង ។
- ក្បួនរថយន្តដឹកជញ្ជូនមិនត្រូវឈប់សំរាកតាមផ្លូវដោយគ្មានការចាំបាច់នោះឡើយ ។ ក្នុងករណីដែលមានការចាំបាច់ក្នុងការឈប់តាមផ្លូវ មន្ត្រីបុគ្គលិក កងការពារសន្តិសុខ និងអ្នកបើកបរទាំងអស់ ត្រូវមានស្មារតីប្រុងប្រយ័ត្នជានិច្ច ដើម្បីអាចគ្រប់គ្រងលើសភាពការណ៍បាន ។
- ក្រៅពីមន្ត្រីបុគ្គលិក កងការពារសន្តិសុខ អ្នកបើកបររថយន្តដែលបានចាត់តាំង និងធនប័ត្រដែលត្រូវដឹកជញ្ជូន គ្មានជនណាផ្សេង ឬទំនិញណាផ្សេងអាចផ្ទុកនៅក្នុងក្បួនរថយន្តដឹកជញ្ជូនបានឡើយ ។

**ប្រការ ៦.-** អគ្គបេឡា និងអគ្គលេខាធិការ ត្រូវធ្វើសេចក្តីណែនាំលំអិតបន្ថែមទៀតចំពោះមន្ត្រីបុគ្គលិករបស់ខ្លួនដែលត្រូវបានចាត់តាំងឱ្យបំពេញបេសកកម្មដឹកជញ្ជូននេះ ។

**ប្រការ ៧.-** រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកដែលមានភារកិច្ចដឹកជញ្ជូនធនប័ត្រ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

ទេសាភិបាល

ធនាគារជាតិនៃកម្ពុជា

ជា-ចាន់តូ

**កន្លែងទទួល :**

- ដូចក្នុងប្រការ ៨

"ដើម្បីអនុវត្ត"

- ឯកសារ- កាលប្បវត្តិ

**ចម្លងជូន :**

- សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- នាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"